**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ២០០.អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការបង្កើតសាលាមធ្យមបច្ចេកទេស

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥កញ្ញា ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ កក្កដា ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ មករា ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែធ្នូ ឆ្នាំ ១៩៩៣ ស្តីពីការរៀបចំ និង ប្រព្រឹត្តទៅ នៃ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨៨ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧ ស្តីពីការប្រែក្លាយ សាលាភូមិន្ទនគរបាល ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សម្រេច**

**មាត្រា១:-**

ត្រូវបានបង្កើតសាលាមធ្យមបច្ចេកទេស ចំណុះបណ្ឌិត្យសភានគរបាលកម្ពុជា នៃក្រសួងមហាផ្ទៃ ។

**មាត្រា២:-**

សាលាមធ្យមបច្ចេកទេសមានឋានៈស្មើ នាយកដ្ឋាន ។ សាលាមធ្យមបច្ចេកទេសដឹកនាំដោយនាយក មួយរូប និង នាយករងមួយចំនួន ជាជំនួយតាមការចាំបាច់ ។

**មាត្រា៣:-**

សាលាមធ្យមបច្ចេកទេស មានភារកិច្ចបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ លើមុខជំនាញបច្ចេកទេស

www.pheakdeylaw.com

នានា ដែលបំរើឱ្យវិស័យនគរបាលជាតិ សំរាប់កម្រិតមធ្យម និង កំរិតចំប៉ិនមុខជំនាញ ។

សាលាមធ្យមបច្ចេកទេស ត្រូវរៀបចំកម្មវិធីសិក្សាកម្រិតមធ្យម ដោយមានការឯកភាពពី បណ្ឌិត្យសភានគរបាលកម្ពុជា ក្រសួងមហាផ្ទៃ និង មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៤:-**

និស្សិតដែលបានរៀនចប់កម្មវិធីសិក្សាកម្រិតមធ្យមបច្ចេកទេស នៅសាលាមធ្យមបច្ចេកទេស និងទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សាត្រូវទទួលសញ្ញាបត្រមធ្យមបច្ចេកទេស តាមមុខជំនាញឯកទេស ដែលបានសិក្សា ។ សញ្ញាបត្រនេះនឹងចុះហត្ថលេខាដោយ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និង កីឡា ។

**មាត្រា៥:-**

លក្ខខណ្ឌនៃការជ្រើសរើសសិស្ស និស្សិត ឱ្យចូលរៀនថ្នាក់មធ្យមបច្ចេកទេសត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៦:-**

ការរៀបចំតួនាទី ភារកិច្ច និង រចនាសម្ព័ន្ធ របស់សាលាមធ្យមបច្ចេកទេស ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា៧:-**

បទបញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

PheakdeyLaw Book Store

**មាត្រា៨:-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង និង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តតាមអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០១១*

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា៨*
- *ឯកសារ-កាលប្បវត្តិ*

www.pheakdeylaw.com